# ចំណាត់ថ្នាក់ឧបករណ៍តន្ត្រីខ្មែរ

ចំណាត់ថ្នាក់ឧបករណ៍តន្ត្រីរបស់ខ្មែរមានទម្រង់មួយជំហានឬមួយជ្រុង។ ជាទូទៅ តន្ត្រីករខ្មែរប្រើការបែងចែកបុរាណជាបីផ្នែកៈ ១.គ្រឿងដំ (គ្រឿងដំ/របៀបលេងឧបករណ៍) ២.គ្រឿងខ្សែ (គ្រឿងខ្សែ/ទ្រង់ទ្រាយ) ៣.គ្រឿងផ្លុំ (គ្រឿងផ្លុំ/របៀបលេងឧបករណ៍)។[៧]

អ្នកស្រី ពេជ សល់ (១៩៧០) បានធ្វើការបែងចែកឧបករណ៍តន្ត្រីក្នុងប្រទេសកម្ពុជា ជាបួនចំណាត់ថ្នាក់ និងឱ្យឈ្មោះដូចតទៅៈ ១.គ្រឿងខ្សែ ២.គ្រឿងផ្លុំ ៣.គ្រឿងពាសស្បែក និង៤. គ្រឿងគោះទង្គិចជាសំឡេង។

ដើម្បីយល់អំពីប្រព័ន្ធនៃចំណាត់ថ្នាក់ឧបករណ៍តន្ត្រីរបស់ខ្មែរ យើងត្រូវពិនិត្យមើលកិរិយាស័ព្ទដែលចង្អុលបង្ហាញពីសកម្មភាពនៃការបង្កើតនិងបន្លឺសំឡេង។ ក្នុងភាសាខ្មែរ គឺយើងប្រើពាក្យ «លេង»។ ជាមួយនឹងឧបករណ៍ទាំងអស់ក្នុងគ្រប់ចំណាត់ថ្នាក់កិរិយាស័ព្ទ «លេង» អាចប្រើបាន។ ទោះបីក្រុមនីមួយៗ ត្រូវបានភ្ជាប់ទៅនឹងកិរិយាស័ព្ទមួយ ដូចជាកិរិយាស័ព្ទ «ដំ» ឬ «វាយ» សម្រាប់ឧបករណ៍គ្រឿងគោះទង្គិចជាសំឡេង និងគ្រឿងពាសស្បែក។ កិរិយាស័ព្ទ «កូត» ឬ «ដេញ» សម្រាប់ឧបករណ៍គ្រឿងខ្សែ។ ឯកិរិយាស័ព្ទ «ផ្លុំ» សម្រាប់ឧបករណ៍គ្រឿងផ្លុំ។ ឧបករណ៍គ្រឿងដំ ឬក្រុមគ្រឿងដំ មានរួមបញ្ចូលនូវអ្វីដែលលោក ហ៊រន បស្តឹល (Hornbostel) និងលោក ហ្សាក់ (Sachs) ហៅថាឧបករណ៍គ្រឿងគោះទង្គិចជាសំឡេង និងគ្រឿងពាសស្បែក។ ពួកគេមិនបែងចែកក្រុមទាំងពីរនេះទេ ដោយសារឧបករណ៍ទាំងពីរប្រភេទនេះ ត្រូវបានតន្ត្រីករ «វាយ» ហើយតន្ត្រីករខ្មែរ ប្រើកិរិយាស័ព្ទ «ដំ» ឬ «វាយ» ក៏ដូចជាមានន័យថា «ដំ»ឬ «វាយ» ដូច្នោះដែរ។

តន្ត្រីករខ្មែរចាត់ថ្នាក់ឧបករណ៍កង្ហួចឬអង្កួច ជាឧបករណ៍គ្រឿងផ្លុំ ដោយឧបករណ៍នេះមានអណ្តាត។ គេប្រហែលជាមានទំនោរទៅលើការប្រតិបត្តិ ជាងអ្នកធ្វើចំណាត់ថ្នាក់នៅលោកខាងលិច គឺដោយសារ បើគិតឱ្យសមហេតុផលទៅ «អណ្តាត» គឺនៅខាងក្នុងមាត់។ តន្ត្រីករខ្មែរ ហៅឧបករណ៍ប៉ីពក ប៉ីប្រប៉ុស និងស្រឡៃ ជាឧបករណ៍គ្រឿងផ្លុំទាំងអស់ ព្រោះវាមាន "អណ្តាត" ហើយឧបករណ៍ទាំងអស់នេះ ត្រូវគេដាក់នៅក្នុងមាត់វាល់ពេល

[៧] Keo and et al. (1994)

អត្ថបទដោយៈ បណ្ឌិត សំ សំអាង

សម្តែង។ លើសពីនេះទៅទៀត គេប្រើកិរិយាស័ព្ទ «ផ្លុំ» ដើម្បីបង្ហាញពីសកម្មភាពសម្តែងឧបករណ៍ទាំងអស់នេះ។

ឧបករណ៍តន្ត្រីមួយនៅកម្ពុជា គឺ «ទ្រសោ» ត្រូវបានគេស្គាល់ថាជា៖

១. គ្រឿងខ្សែ (ឧបករណ៍គ្រឿងខ្សែ)

២. គ្រឿងកូត (ឧបករណ៍គ្រឿងកូត)

៣. គ្រឿងមហោរី (ឧបករណ៍ប្រើក្នុងវង់ភ្លេងមហោរី)

ចំណែកឯ «រនាតឯក» វិញ ត្រូវបានគេបែងចែកចំណាត់ថ្នាក់ដូចតទៅ៖

១. គ្រឿងដំ (ឧបករណ៍គ្រឿងដំ/បច្ចេកទេសសម្តែង)

២. គ្រឿងពិណពាទ្យ (ឧបករណ៍ពិណពាទ្យ/ប្រភេទវង់ភ្លេង)

៣. គ្រឿងមហោរី (ឧបករណ៍មហោរី/ប្រភេទវង់ភ្លេង)

៤. គ្រឿងនាំ (ឧបករណ៍នាំ/តួនាទី)

៥. គ្រឿងតន្ត្រីបុរាណ (ឧបករណ៍តន្ត្រីបុរាណ/ទម្រង់)

សៀវភៅមួយអំពីឧបកតណ៍តន្ត្រីនៅប្រទេសកម្ពុជា មានចំណាត់ថ្នាក់តន្ត្រីបួនក្រុម គឺ៖ គ្រឿងផ្លុំ គ្រឿងខ្សែ គ្រឿងដំ (ប្រភេទរនាត គង និងស្គរ) និងគ្រឿងផ្សេងៗ។[២] អ្នកស្រី ពេជ សល់ ក៏បានចាត់ថ្នាក់តន្ត្រីជាបួនក្រុមដែរ តែខុសគ្នាបន្តិចគឺ៖ គ្រឿងខ្សែ គ្រឿងផ្លុំ គ្រឿងដំ (ស្គរ) និងគ្រឿងដំ (ប្រភេទរនាតនិងគង)។[៣]

ប្រព័ន្ធតន្ត្រីនៅកម្ពុជា គឺមានឫសគល់ជ្រៅពាក់ព័ន្ធទៅនឹងវប្បធម៌និងកេរដំណែលខ្មែរ។ ទ្រឹស្តីនិងការអនុវត្តតន្ត្រីខ្មែរ រួមទាំងគំនិតនិងចំណាត់ថ្នាក់តន្ត្រីបានបន្តពីគ្រូទៅសិស្សនៅក្នុងរង្វង់និងបរិបទផ្ទេរចំណេះដឹងការសម្តែង។

ប្រព័ន្ធចំណាត់ថ្នាក់ឧបករណ៍តន្ត្រី ដែលប្រើរូបភាពឧបករណ៍ជាលក្ខណៈវិនិច្ឆ័យ គឺមិនបានយកកត្តាបទពិសោធន៍តន្ត្រីមកបញ្ចូលទេ។ នៅក្នុងអត្ថបទនេះ ខ្ញុំយកការអនុវត្តខ្មែរដាក់ស្តែងជាមូលដ្ឋាន ដោយមិនបង្ខំយកឧបករណ៍តន្ត្រីណាមួយទៅដាក់នៅក្នុង

[២] Keo and et al. (1994)

[៣] ពេជ សល់ ១៩៧០: ១៦

ប្រព័ន្ធដើម្បីឱ្យស្របទៅតាមការគំនិតនិងសំយោគមតិរបស់ខ្ញុំនោះឡើយ។ ពោលគឺ វាជាកាតព្វកិច្ចរបស់យើងក្នុងការរកឱ្យឃើញការពិតរបស់វា។

ប្រព័ន្ធចំណាត់ថ្នាក់ឧបករណ៍តន្ត្រីរបស់លោក ហ៊ិរន បស្តឹល-ហ្សាក់ (Hornbostel-Sachs) ជាទស្សនៈទ្រឹស្តីមជ្ឈមណ្ឌល (Theory-centered concept)។ ចំណែកឯប្រព័ន្ធចំណាត់ថ្នាក់ឧបករណ៍តន្ត្រីខ្មែរគឺ ការសម្តែងមជ្ឈមណ្ឌល (Performance-centered)។ ពោលគឺខ្មែរបង្កើតប្រព័ន្ធខ្មែរក្នុងគោលបំណងបម្រើការអនុវត្តជាក់ស្តែងនិងការម្តែងតន្ត្រីសុទ្ធសាធ មិនមែនដើម្បីចំណាត់ថ្នាក់តន្ត្រីឬសារមន្ទីរវិទ្យាឡើយ។

តន្ត្រីករខ្មែរចាត់ថ្នាក់ឧបករណ៍តន្ត្រីរបស់គេទៅតាម៖

- បុគ្គលិកលក្ខណៈនិងការសម្តែងរបស់ឧបករណ៍តន្ត្រី គឺ៖ ខ្សែ គោះ និង ដំ
- តួនាទីរបស់ឧបករណ៍៖ ដឹកនាំឬចំណាត់ថ្នាក់ (ឯក)
- ស្ទីលតន្ត្រី៖ រត់ (រនាតរត់)
- វង់តន្ត្រី៖ បរិបទ អារក្ស អាពាហ៍ពិពាហ៍ ពិណពាទ្យ ឬមហោរី
- ស្ថានភាពគ្រប់គ្រងសកម្មភាពដោយ៖ មាត់ប្រើជាមួយនឹងគ្រឿងផ្លុំដូចជាកន្លួច (អន្លូប)
- ទំហំ៖ តូចឬធំ
- ប្រភេទ៖ ព្រះរាជទ្រព្យនៅក្នុងព្រះបរមរាជវាំង ឬប្រពៃណីនៅជាមួយនឹងប្រជាជន
- ជំនឿ៖ សាសនា សក្ការៈ ឬសាមញ្ញ

សំណួរមួយដែលយើងអាចសួរពីប្រព័ន្ធខ្មែរគឺថា តើខ្មែរយើងចាត់ថ្នាក់ឧបករណ៍តន្ត្រី ឬយើងគ្រាន់តែរៀបរាប់ជាបញ្ជី និងអធិប្បាយអំពីឧបករណ៍តន្ត្រីទាំងនេះ។ យើងនឹងនៅមានចំណាត់ឧបករណ៍តន្ត្រីនាពេលអនាគតទៀត ដរាបណាយើងនៅមិនទាន់មានការយល់ព្រមនិងទទួលស្គាល់ណាមួយជាសកលនៅឡើយ។

មកទល់នឹងបច្ចុប្បន្នកាលនេះ ប្រភពបស្ចិមប្រទេសល្បោះល្បាយ ស៊ីជម្រៅជាច្រើនបានពិភាក្សាអំពីចំណាត់ថ្នាក់ឧបករណ៍តន្ត្រី ជាពិសេសពាក់ព័ន្ធនឹងនិយមន័យ។ ពិនិត្យទៅលើនិយមន័យទាំងនោះ យើងឃើញថាអ្វីៗដែលខ្ញុំសរសេរនៅទីនេះ គឺទាក់ទងនឹងទៅ

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

នឹងប្រភេទចំណាត់ថ្នាក់ឧបករណ៍តន្ត្រីរបស់លោក ម៉ែនតឹល ហ៊ុដ (Mantle Hood) ដែលមាននិយមន័យនិងអត្ថន័យខ្លឹមសារថា វិទ្យាសាស្ត្រនៃឧបករណ៍តន្ត្រី រួមបញ្ចូលទាំងការពិពណ៌នា បច្ចេកទេសសម្តែង ការបម្រើតន្ត្រី ការតុបតែងលម្អ ព្រមទាំងការគិតបញ្ចូលទាំងកត្តាសង្គមវប្បធម៌ទៀតផង។[៦]

## ឯកសារយោង

ពេជ សល់. (១៩៧០). *អំពីលំនាំសង្ខេបនៃភ្លេងខ្មែរ*. ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ។

Hood, Mantle. (1982). *The Ethnomusicologist*. Kent, OH: Kent State University Press.

Hornbostel, Eric M. von, and Sachs, Curt. (1961). A Classification of Musical Instruments, *Galpin Society Journal*, (14):3-29.

Jenkins, Jean, Ed. *Ethnic Musical Instruments: Identification-Conservation*. London: International Council of Museums.

Keo, Dorivan, et al. (1994). *Traditional Musical Instruments of Cambodia*. Phnom Penh: UNESCO.

Sam, Sam-Ang. (2001). *Musical Instruments of Cambodia*. Osaka: National Museum of Ethnology.

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

[៦] 1982: 124



អត្ថបទដោយ៖ បណ្ឌិត សំ សំអាង



អត្ថបទដោយៈ បណ្ឌិត សំ សំអាង





អត្ថបទដោយ៖ បណ្ឌិត សំ សំអាង





អត្ថបទដោយ៖ បណ្ឌិត សំ សំអាង



KHMER CIVILIZATION

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង



អត្ថបទដោយ៖ បណ្ឌិត សំ សំអាង